ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៨៥)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៤ ៥១៧នាក់ នៃសហគ្រាសទាំង៥១ នៃវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលសហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។

ក្រសួងសូមរំឭកថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខាន មិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅសហគ្រាសទាំង៥១ នេះ មិនបានទទួលសារទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួនទៅរដ្ឋបាលសហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មករសហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

*ថ្ងៃ ចន្ទ ៣កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦*

*រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០២២*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

### ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២២

### បញ្ជីឈ្មោះ សហគ្រាស ក្នុងវិស័យទេសចរណ៍
### ចំនួន ៥១ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះសហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| វិស័យទេសចរណ៍ | | 51 |
| 1 | ក្រុមហ៊ុន សិប្បករអង្គរ ភ្នំពេញ | ភ្នំពេញ |
| 2 | សណ្ឋាគារ រ៉េស៊ីដង់ សុខាភ្នំពេញ | ភ្នំពេញ |
| 3 | ក្រុមហ៊ុន អេស៊ា អិចផ្លរើ ត្រាវែល | ភ្នំពេញ |
| 4 | ក្រុមហ៊ុន សិប្បករអង្គរ | សៀមរាប |
| 5 | ផ្ទះសំណាក់បាបែល | សៀមរាប |
| 6 | សណ្ឋាគារសុខាសៀមរាប | សៀមរាប |
| 7 | សណ្ឋាគារ សុខាអង្គរ | សៀមរាប |
| 8 | ភោជនីយដ្ឋាន នារីខ្មែរ | សៀមរាប |
| 9 | អាហារដ្ឋានផ្ទះបាយខ្មែរភឿក | សៀមរាប |
| 10 | ក្រុមហ៊ុន ជាតិថាតា អង្គរ | សៀមរាប |
| 11 | ផ្ទះសំណាក់ សាតូអង្គ | សៀមរាប |
| 12 | ក្រុមហ៊ុន អេប៊ិច ខេមបូឌា ត្រាវ៉ែល ស៊ែរវីស | សៀមរាប |
| 13 | ក្រុមហ៊ុន ទន្លេសាបចៅផាយ៉ា (ភោជនីយដ្ឋានទន្លេសាប) | សៀមរាប |
| 14 | ក្រុមហ៊ុន ទន្លេសាបចៅផាយ៉ា (ភោជនីយដ្ឋានទន្លមេគង្គ) | សៀមរាប |
| 15 | ក្រុមហ៊ុន ទន្លេសាបចៅផាយ៉ា (អង្គរធីខេត្រាវែល ធួរ) | សៀមរាប |
| 16 | សណ្ឋាគារ បាយ័ន អេរ៉ា ហូថែល ឧបភើរសេិន | សៀមរាប |
| 17 | ក្រុមហ៊ុន កាឡាស ខម (ខេមបូឌា) ភីធីអ៊ី អិលធីឌី (សណ្ឋាគារ អង្គរ អេរ៉ា) | សៀមរាប |
| 18 | ក្រុមហ៊ុន ហ្គោលដេន ទ្រី ព្រីនស៍ ហូថែល និងស្ប៉ា | សៀមរាប |

| ល.រ | ឈ្មោះសហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 19 | ក្រុមហ៊ុន ដំរីអង្គរ ខូ អិលធីឌី | សៀមរាប |
| 20 | ក្រុមហ៊ុន អេមព្រីស អង្គរ | សៀមរាប |
| 21 | ក្រុមហ៊ុន ខមហ្វតប្រជីធី សីលូសិន (ខូអិល ធីឌី) | សៀមរាប |
| 22 | សណ្ឋាគារ លីនាយាអង្គរ រីសត និងស្ប៉ា | សៀមរាប |
| 23 | សណ្ឋាគារប៉ាវ៉ាឌីសអង្គរវីឡា | សៀមរាប |
| 24 | ក្រុមហ៊ុន អេរីតាស II | សៀមរាប |
| 25 | ក្រុមហ៊ុន អង្គរ ហូលីដេ | សៀមរាប |
| 26 | ក្រុមហ៊ុន សាលាឡូដ | សៀមរាប |
| 27 | សណ្ឋាគារប៉ាស៊ីហ្វិក | សៀមរាប |
| 28 | សណ្ឋាគារ ឃីងដុម អង្គរ | សៀមរាប |
| 29 | សណ្ឋាគារ សាឯមសៀមរាប | សៀមរាប |
| 30 | សណ្ឋាគារសោមាទេវីអង្គររីសត & ស្ប៉ា | សៀមរាប |
| 31 | សណ្ឋាគារ ស្វាយលើង | សៀមរាប |
| 32 | សណ្ឋាគារតាព្រហ្ម | សៀមរាប |
| 33 | សណ្ឋាគារ អង្គរប៉ារ៉ាឌី | សៀមរាប |
| 34 | ក្រុមហ៊ុន បុរី អង្គរ | សៀមរាប |
| 35 | សណ្ឋាគារ អង្គរមីរ៉ាខល រីហ្សត និង ស្ប៉ា | សៀមរាប |
| 36 | សណ្ឋាគារសុខាល័យអង្គរ រីហ្សត និងស្ប៉ា | សៀមរាប |
| 37 | ក្រុមហ៊ុន ឡូទុស ប្លង្គ រីសត | សៀមរាប |
| 38 | ក្រុមហ៊ុន អញ្ជលី បាយ ស៊ីផុន | សៀមរាប |
| 39 | សណ្ឋាគារ អូរៀនថល ដេ7 | សៀមរាប |
| 40 | សណ្ឋាគារដឹឡាពេ (ផាកហៃយ៉ាត់សៀមរាប) | សៀមរាប |
| 41 | សណ្ឋាគារ តារា អង្គរ | សៀមរាប |
| 42 | សណ្ឋាគារ ខ្មែរអង្គរហូថែលកូអិលធីឌី | សៀមរាប |
| 43 | សណ្ឋាគារ ម៉េម៉រ អង្គរ | សៀមរាប |
| 44 | សណ្ឋាគារ អង្គរ | សៀមរាប |
| 45 | សណ្ឋាគារស្ទឹងសៀមរាបថ្មី | សៀមរាប |

| ល.រ | ឈ្មោះសហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 46 | សណ្ឋាគារគោព្រៃ | សៀមរាប |
| 47 | សណ្ឋាគារ មុទិតា រីសត & ស្ប៉ា | សៀមរាប |
| 48 | សណ្ឋាគារសុខៈប៊ូទិក | សៀមរាប |
| 49 | សណ្ឋាគារ អង្គរតែលេសរីហ្សត និងស្ប៉ា | សៀមរាប |
| 50 | សណ្ឋាគារ សិន្តា មុន្នី | សៀមរាប |
| 51 | ក្រុមហ៊ុន ថ្មរូង ឌីវេឡុបមេន | ព្រះសីហនុ |